សេចក្តីប្រកាសព័ត៌មានរួម
សម្រាប់ការចេញផ្សាយភ្លាមៗ

# ផ្សារទំនើប អ៊ីអនម៉ល និង ធនាគារ ABA សហការក្នុងការបង្កើនការទូទាត់ដោយមិនប្រើសាច់ប្រាក់សម្រាប់ប្រជាជនកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី 19 ខែ តុលា ឆ្នាំ 2021-** ធនាគារ ABA ជាធនាគារឈានមុខផ្នែកសេវាធនាគារឌីជីថលនៅកម្ពុជា និង ផ្សារទំនើប អ៊ីអនម៉ល ជាក្រុមហ៊ុនឯកទេសអភិវឌ្ឍ និងប្រតិបត្តិការផ្សារទំនើបដែលកំពុងគ្រប់គ្រងលើ AEON MALL Phnom Penh និង AEON MALL Sen Sok City បានចុះកិច្ចព្រមព្រៀងលើការទទួលការទូទាត់ប្រាក់បែបអេឡិចត្រូនិច ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់អតិថិជន AEON MALL ។

ក្រោមភាពជាដៃគូនេះ អតិថិជន ABA នឹងពុំចាំបាច់ពិបាកក្នុងការកាន់ក្រដាសប្រាក់ដើម្បីទូទាត់ទៀតឡើយ ដោយគ្រាន់តែស្កេន ABA PAY QR codes នៅបញ្ជរបង់ប្រាក់តាមរយៈ ABA Mobile។ លោកអ្នកអាចស្កេនQR codes ដើម្បីទូទាត់បានជាង 200ហាង និងផ្សារទំនើបទាំងពីរសាខារបស់ AEON MALL ។ ABA QR codes នេះក៏អាចប្រើប្រាស់ក្នុងម៉ាស៊ីនទូទាត់ POS និងជើងបញ្ឈរ QR ( Static Stand ) ដែលនាំមកនូវភាពងាយស្រួល និងសុវត្ថិភាពដល់ការទូទាត់ប្រាក់។

បន្ថែមពីនេះទៅទៀត ធនាគារ ABA ក៏បានក្លាយជាដៃគូយុទ្ធសាស្ត្ររបស់ AEON MALL Sen Sok City ក្នុងការផ្តល់ជូននូវឧបករណ៍ប្រមូលសាច់ប្រាក់ដែលទំនើប និងសុវត្ថិភាពតាមរយៈមាស៊ីនស្វ័យធនាគារ និងបញ្ជរ។ ក្នុងពេលជាមួយគ្នានេះដែរ AEON MALL នឹងប្រើប្រាស់ ABA ធនាគារអាជីវកម្មអនឡាញសម្រាប់អាជីវកម្ម ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឲ្យគ្រប់ជ្រុងជ្រោយ។

លោក Tsuboya Masayuki អគ្គនាយកក្រុមហ៊ុន AEON MALL បានមានប្រសាសន៍ក្នុងឱកាសនេះថា "ជាបឋមយើងខ្ញុំសូមសម្តែងនូវការពេញចិត្ត និងកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយជាមួយធនាគារ ABA។" យើងខ្ញុំជឿជាក់ថា អតិថិជនរបស់យើងនឹងរីករាយជាមួយនឹងការសហការលើការទូទាត់ប្រាប់បែបអេឡិចត្រូនិចនៅក្នុងផ្សារទំនើបរបស់យើង។ ជាចុងបញ្ចប់ AEON MALL មានបំណងផ្តល់នូវបរិយាកាសរស់នៅបែបកម្សាន្តជូនអតិថិជនដូចនឹងបេសកកម្មរបស់យើង "បំពេញជីវភាពប្រចាំថ្ងៃ នៅកម្ពុជា ជាមួយនឹងលទ្ធភាពថ្មី "។

លោក Madi Akmambet អភិបាលប្រតិបត្តិនៃធនាគារ ABA មានប្រសាសន៍ថា៖ "យើងមានសេចក្តីរីករាយក្នុងការប្រកាសជាផ្លូវការពីភាពជាដៃគូរលើការទូទាត់ប្រាក់បែបអេឡិចត្រូនិច និងសេវាប្រមូលសាច់ប្រាក់។ ពួកយើងជឿជាក់ថា

ដំណោះស្រាយដែលទំនើប និងងាយស្រួលរបស់ ABA នឹងផ្តល់អត្ថប្រយោជន៍ដល់ពាណិជ្ជករ ក៏ដូចជាអតិថិជនរបស់ AEON MALL រាប់លាននាក់របស់យើង។ នេះគឺជាការបន្តការរួមចំណែករបស់ធនាគារ ABA ក្នុងការចូលរួមអភិវឌ្ឍបន្ថែម លើវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ននៅក្នុងប្រទេសកម្ពុជា។"

ធនាគារ ABA និងផ្សារទំនើប អ៊ីអនម៉ល គឺជាស្លាកសញ្ញាល្បីឈ្មោះមួយក្នុងប្រទេសកម្ពុជានៅលើវិស័យទីផ្សាររបស់ខ្លួន។ ដោយសារតែការផ្លាស់ប្តូរឌីជីថល និងធនាគារឌីជីថល អាចឲ្យធនាគារ ABA ក្លាយជាស្ថាប័នធនាគារ និងហិរញ្ញវត្ថុឈាន មុខគេក្នុងប្រទេសកម្ពុជាទាំងក្នុងស្រុក និងជាសកល។ ដូចគ្នានេះដែរ ផ្សារទំនើប អ៊ីអនម៉ល បានក្លាយជាស្លាកសញ្ញាល្បី ឈ្មោះក្នុងការផ្តល់នូវបទពិសោធន៍ទិញទំនិញដែលផ្តោតលើទំនិញមានគុណភាពខ្ពស់ និងសេវាកម្មល្អក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ 2014។

សម្រាប់ព័ត៌មានបន្ថែមរបស់ ABA និង AEON MALL សូមទំនាក់ទំនងមកកាន់ 023 988 100 សម្រាប់ AEON MALL ឬ 023 225 333 សម្រាប់ ABA។

**អំពី AEON MALL**

អ៊ីអនម៉ល គឺជាក្រុមហ៊ុនមួយ នៃអ៊ីអនគ្រុបជប៉ុន ដែលកំពុងប្រតិបត្តិការនៅប្រទេសកម្ពុជា មានឯកទេសផ្នែកអភិវឌ្ឍន៍ និង ប្រតិបត្តិការផ្សារទំនើប ។ ដោយមានផ្សារទំនើបទី ៣ គ្រោងនឹងបើកដំណើរការ នាចុងឆ្នាំ ២០២២ រួមនឹងការពង្រីកទំហំផ្សារ ទំនើបទី ១ ធ្វើអោយផ្សារទំនើបអ៊ីអនម៉ល នឹងក្លាយជាផ្សារទំនើបធំជាងគេបង្អស់ ដែលមានផ្ទៃហាងសរុប លំដាប់កំពូលទាំង ៣ នៅប្រទេសកម្ពុជា ហើយអាចបំពេញតម្រូវការ និងជួយសម្រួល កម្រិតជីវភាពប្រចាំថ្ងៃ របស់អតិថិជន ជាមួយនឹងបេសកកម្មចំ បងគឺ "បំពេញជីវភាពប្រចាំថ្ងៃ នៅកម្ពុជា ជាមួយនឹងលទ្ធភាពថ្មី" ។
សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.aeonmallcambodia.com.

អ៊ីអនគ្រុប គឺជាក្រុមហ៊ុនមេរបស់អ៊ីអនម៉ល ហើយជាសាជីវកម្មពាណិជ្ជកម្មលក់រាយធំបំផុតមួយ នៅលើពិភពលោកដែលមាន ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នាចំនួន ១៧៩ នៅក្នុងនិងក្រៅប្រទេសជប៉ុន។ អ៊ីអនគ្រុបមាន អាជីវកម្មធំៗ ចំនួន១០នៅក្នុងការ អភិវឌ្ឍន៍ប្រកបដោយតុល្យភាពក្រោមរចនាសម្ព័ន្ធក្រុមហ៊ុនមេសុទ្ធសាធ។ ក្រៅពីសកម្មភាពអាជីវកម្ម អ៊ីអនគ្រុប ចូលរួមក្នុង ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន ក្នុងគោលបំណងលើកកម្ពស់សកម្មភាពសង្គមក្នុងតំបន់។
សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.aeonmall.com.

**អំពីធនាគារ ABA**

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1996។ ជាមួយសាខា 79, ម៉ាស៊ីន ATM 379, ម៉ាស៊ីនទូទាត់ POS ចំនួន 2498, ម៉ាស៊ីនស្វ័យសេវា 344 ទូទាំងប្រទេស និងសេវាធនាគារអនឡាញ ឈានមុខ ធនាគារ ABA ផ្តល់សេវាហិរញ្ញវត្ថុដ៏ទំនើបជាច្រើនជូនអតិថិជនរបស់ខ្លួនជាង 1.7 លាននាក់ ក្នុងផ្នែកផ្សេងៗជាច្រើន ដូចជា រូបវន្តបុគ្គល, អាជីវកម្មខ្នាតតូច, និងសហគ្រាសធុនតូច និងមធ្យម។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.ababank.com។
ធនាគារ ABA គឺជាបុត្រសម្ព័ន្ធរបស់ធនាគារជាតិកាណាដា ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុ មានទ្រព្យសកម្មជាង 283 ប៊ីលានដុល្លារ

គិតត្រឹមថ្ងៃទី 31 ខែកក្កដា 2021។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្ត នៃប្រទេសជាមួយនឹងអតិថិជនក្នុងដៃ 2.7 លាននាក់។ ជាគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី 6 ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេបិច ធនាគារជាតិកាណាដា ជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានានៅទីនោះ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.nbc.ca។

**ទំនាក់ទំនង**


ផ្សារទំនើប AEON MALL
Tola Thun
អនុប្រធានផ្នែកផែនការសាជីវកម្ម
ទូរស័ព្ទ៖ +855 10 511 312
អ៊ីមែល៖ tolat@aeonmll-kh.com

ធនាគារ ABA
Chiva Chan
អ្នកគ្រប់គ្រងទំនាក់ទំនងសាធារណៈ
ទូរស័ព្ទ៖ +855 98 630 281
អ៊ីមែល៖ chan.chiva@ababank.com